D00013 ⑬ TS

សំភាសជាមួយស.ម ម៉ាន់ លេង

ថ្ងៃ ខែ ឆ្នាំ ......
ទីកន្លែង ស្រុកត្រាំកក់ខេត្តតាកែវ
ម៉ោង ....

ក្នុងនាមខ្ញុំជាឃោសនាការ និង វប្បធម៌មជ្ឈិម ហើយក្នុងនាមគណៈកម្មការស្រាវជ្រាវឧក្រិដ្ឋកម្ម ថ្ងៃនេះបានមកជួបប្អូន សូមប្អូននិយាយរៀបរាប់យ៉ាងណាអំពីឧក្រិដ្ឋកម្ម ដែលបានឃើញ ហើយអំពីការសាងសង់គុកនៅក្រាំងតាចាន់ ហើយនិងយើងខ្ញុំចង់អោយគូរជារូបសំណាកគុកមួយ ដើម្បីជាភស្តុតាងជាក់ស្តែង ដូច្នេះសូមប្អូនរៀបរាប់ និង មានយោបល់យ៉ាងណា ?

ខ្ញុំឈ្មោះម៉ាន់ លេង សព្វថ្ងៃ អាយុ ៣២ ឆ្នាំ ឪពុកឈ្មោះ ណុប ម៉ាន់ ម្តាយឈ្មោះ ទោ យ៉ត ម្តាយខ្ញុំស្លាប់តាំងពីខ្ញុំនៅតូចៗ ក្រោមការឧបត្ថម្ភរបស់ឪពុក ឪពុកខ្ញុំបានបញ្ជូនខ្ញុំអោយទៅរៀន រហូតបានប្រឡងជាប់មធ្យមសិក្សាបឋមភូមិ ខ្ញុំបានបន្តវិជ្ជារៀននៅភ្នំពេញ តែដោយមានការខ្វះខាតផ្នែកខាងជីវភាពដោយឪពុកត្រូវបានក្បត់កៀរយកទៅអោយនៅលើភ្នំ ម្ល៉ោះហើយខ្ញុំក៏ឈប់រៀនមកនៅឯតាកែវក្រោយមកដោយយល់ពីសភាពការណ៍ស្រុកទេសបានខ្លះៗ ខ្ញុំក៏រត់ចូលខ្មែរក្រហមក្នុងឆ្នាំ ១៩៧៣ ចូលមកដល់វាបានបញ្ជូនខ្ញុំអោយនៅគុកព្រៃត្រជួច សព្វថ្ងៃជាមូលដ្ឋានរបស់ឃុំ តាផេម ក្នុងស្រុកត្រាំកក់ ក្រោយមកទៀតខ្ញុំបានលួចរត់ចេញពីព្រៃត្រជួច នៅតាមឪពុកម្តាយនៅឯឃុំសោមស្រុកគីរីវង្ស នៅក្នុងឆ្នាំ ១៩៧៦ ដោយពេលនោះគេបែងចែកប្រជាជនពេញសិទ្ធិហើយនិងប្រជាជន ១៧ មេសា ខ្ញុំក៏ត្រូវធ្លាក់មកត្រឹមប្រជាជនបញ្ញើរ គេអោយមកនៅឃុំ ស្រែរនោងដល់ថ្ងៃទី ៣០.. ថ្ងៃទី ៣០ គឺជាថ្ងៃមិទិញធំរបស់គេ គេបានបើកសិទ្ធិអោយប្រជាជនទាំងអស់ទៅឡើងបរិហារកេរ្តិ៍ របស់រដ្ឋអំណាចគេ ខ្ញុំដឹងថានេះជាលេសសំរាប់សម្លាប់មនុស្ស .. ប៉ុន្តែខ្ញុំត្រូវតែហ៊ាននិយាយទី ១ បញ្ហាសំលាប់មនុស្ស គ្មានការរកយុត្តិធម៌អោយប្រជាជនលុះដល់និយាយចប់ថ្ងៃទី ១ គេមិនទាន់ចាប់ខ្ញុំទេ ថ្ងៃទី ២ បានវាចាប់ក៏ប៉ុន្តែខ្ញុំ នៅឆ្នាំ ១៩៧៧ ទើបគេរកចាប់ ខ្ញុំដឹងខ្លួនដោយសារលោកតា ញាញ់ កូនគាត់ឈ្មោះ ញឹម ជាប្រធានកង ហើយលោកតាញាញ់គាត់ស្រលាញ់រាប់អានខ្ញុំដូចជាកូនបង្កើតក្នុងពេលហ្នឹងខ្ញុំនៅផ្ទះគាត់ គាត់និយាយប្រាប់ថាអោយខ្ញុំរត់ចេញ ហើយខ្ញុំនៅទីនោះ វង្វេងមិនដឹងរត់ទៅទីណា គាត់អោយរត់ទៅទិសខាងកើត ខ្ញុំរត់ម្តងហើយពេលយប់ ម្ល៉ោះហើយរកផ្លូវមិនឃើញត្រឡប់មកវិញ ដល់ពេលថ្ងៃរះទើបចាប់រត់តទៅទៀត ៣ ថ្ងៃទើបខ្ញុំ រហូតដល់ទួលដែន ចូលទៅដល់ទួលដែនគេចាប់ជាប់នៅឃុំ តាកព្រិច រួចមកគេបញ្ជូនខ្ញុំដោយមានការដោះស្រាយដើម្បីរួចខ្លួន គេក៏យល់ស្រប ទៅតាមគំនិតរបស់ខ្ញុំ រួចគេបញ្ជូននៅឃុំ សោមវិញ ដល់ក្រោយមកទៀត ពេលហ្នឹងចលនាតស៊ូ របស់បដិវត្តជិតបានវាយប្រានមកចូលឃុំសោមធ្លាយរហូតមកដល់ស្រុក មកដល់ខាងកើតព្រៃសណ្តែក ខ្ញុំក៏នាំឪពុកភៀសខ្លួនមក ដោយឈ្មោះខ្ញុំគេរកចាប់ ឃុំញ៉ាំងញ៉ាំង ក៏គេរកចាប់ ឃុំស្រែរនោង និង ឃុំតាផេម ទាំងបីភូមិហ្នឹងក៏គេរកចាប់ឈ្មោះខ្ញុំ ខ្ញុំបានមកលួចរស់ក្នុងភូមិអង្គតាសោមពីរខែ មកដកតែនឹងព្រៃ ក្រោយមកទៀតខ្ញុំក៏វិលមកវិញ វិលត្រឡប់ទៅរកឪពុកម្តាយវិញ វិលទៅគេចាប់ជាប់នៅស្រែរនោង ឃុំស្រែរនោង គេបញ្ជូនខ្ញុំ រួចមកគេបញ្ជូនទៅនៅសាលាឃុំវិញ បានមួយថ្ងៃមួយយប់ គេវាយធ្វើបាបយ៉ាងសាហាវរួចមកគេបញ្ជូនខ្ញុំទៅក្រាំងតាចាន់ ចូលក្រាំងតាចាន់... គេ..ក្នុង ចូលទៅដល់បីថ្ងៃមុនដំបូងគេមិនទាន់ធ្វើអ្វីទេ ចូលដល់ថ្ងៃទី ១ គេសួរចំលើយ ៣ថ្ងៃគេសួរម្តង..ក្នុងម្តងគេវ៉ៃ សន្លប់ពីរដង អស់រយៈពេល ៧ថ្ងៃ គេបានបញ្ជូនខ្ញុំដឹករទេះគោខ្ញុំទៅកាត់តាមព្រៃភ្នំខ្ញុំអត់ស្គាល់ដែរ ពីព្រោះវាវ៉ៃខ្ញុំនិងកាំភ្លើងអស់រយៈពេលពីរខែទើបវាបញ្ជូនខ្ញុំមកខេត្តតាកែវ មកនៅខាងមុខសណ្ឋាគារខេត្ត កន្លែង... កន្លែងជាប់គុកដែលគេដាក់ក្នុងនោះ ខ្ញុំជាប់ជាមួយវៀតណាមម្នាក់ដែលគេ

...២...

ចាប់បានពីភ្នំដិនមក ចាប់បានពីសមរភូមិ ទំរដោះបាន ៤ថ្ងៃ គេសំរេចថាសំរាលទោសខ្ញុំ អោយខ្ញុំមកសំរាលទោសនៅអង្គការ ដែលឡុបធានគុកមានមិត្តម៉េងជាប្រធាន ហើយក្រោមការគ្រប់គ្រងរបស់សមាជិកស្រុកឈ្មោះ ឈឿន អតីតៈពេទ្យក្នុងឃុំសំរោង ក្រោយមកបានបីខែហ្នឹងខ្ញុំដើររួច ខ្ញុំទៀតដើរបានរួចក៏លួចរត់ចេញពីហ្នឹងទៀត មកដល់ភូមិឈើទាលប្រកៀប ៣ថ្ងៃបានមកដល់. ខ្ញុំបានដេកនៅក្បែរអង្គតាសោម មុខមន្ទីរអប់រំបច្ចុប្បន្ន រួចមកខ្ញុំលួចឡើងតាមឡាន រួចទៅនៅស្រុកក្រោម រហូតដល់ខែបកថ្ងៃទី ១-១- កងទ័ពវៀតណាមចូលមករំដោះ ខ្ញុំក៏ចូលទៅក្នុងកងទ័ពវៀតណាមតាំងពីថ្ងៃ ១-១-៧៩ តែដោយខ្ញុំមានភាពទ្រុឌទ្រោមផ្នែកសុខភាពខ្លាំងពេកតាំងពីដំនាន់ ប៉ុល ពត អៀង សារី ខ្ញុំក៏ចេញមកក្នុងជាប្រជាជនវិញ មកដល់បច្ចុប្បន្ននេះអង្គការបានយកខ្ញុំមកធ្វើការក្នុងមន្ទីរឃោសនាការរហូតមកដល់សព្វថ្ងៃនេះ ។

គំនូរដែលប្អូនបានគូរ ហើយដែលគណៈកម្មាការឃើញខ្ញុំបានថតអម្សិញមិញនេះ ប្អូនឃើញនៅកន្លែងណា ? សូមប្អូនរៀបរាប់បន្តិចមើល ?

គំនូរដែលខ្ញុំបានគូរទាំងប៉ុន្មាននេះ គឺភាពជាក់ស្តែងជាវិធីមួយដែលសម្លាប់មនុស្សនៅក្នុងរបបប្រល័យពូជសាសន៍ ប៉ុល ពត អៀង សារី គឺមានទាំងចាក់ ចាប់បោក កូនក្មេងនិងគល់ឈើ មានតាំងពីចាក់កនារី មានតាំងពីវៃត្បងចប ដោយសល់ឬលីរូមុននឹងវាដាក់ចូលក្នុងរណ្តៅ គឺវាអារក ហើយវះពោះ បានដាក់ចូលក្នុងរណ្តៅ ហើយក្នុងមួយរណ្តៅវាមាន ៣០០ ទៅ ៤០០ តាមរណ្តៅតូចធំ ហើយនៅវិធីសម្លាប់ផ្សេងៗ ជាច្រើនទៀត ប៉ុន្តែខ្ញុំមិនបានគូរជារូប ព្រោះខ្ញុំអត់បានឃើញពិតប្រាកដ ។